# សេចក្ដីថ្លែងការណ៍រួម

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៦*

## ក្រុមសង្គមស៊ីវិលចំនួន ៥0 ប្រកាសគាំទ្រពហិការចំពោះក្រុមហ៊ុនទេសចរណ៍ កាពីតូល បន្ទាប់ពីមានការបង្ក្រាបទៅលើសកម្មភាពរបស់សហជីព ដ៏ឃោរឃៅបានកើនឡើង

ជាការឆ្លើយតបទៅនឹងការវាយប្រហារដ៏ឃោរឃៅទៅលើការតវ៉ារបស់កម្មករកាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ យើងជាសហជីព តំណាងសហគមន៍ និងអង្គការសង្គមស៊ីវិលមានរាយនាមខាងក្រោម (“សង្គមស៊ីវិល”) សូមប្រកាសគាំទ្រពេញទំហឹងចំពោះការធ្វើពហិការជាបន្តបន្ទាប់ចំពោះក្រុមហ៊ុនកាពីតូល ខូ អិល.ធី.ឌី ដែលគេស្គាល់ថាកាពីតូលទេសចរណ៍ និងសូមអំពាវនាវដល់សាធារណជនទូទៅចូលរួមពហិកានេះជាមួយគ្នា ដោយសារតែក្រុមហ៊ុនបានបណ្ដេញចេញនិយោជិតរបស់ខ្លួនដោយពុំត្រឹមត្រូវ និងបង្ក្រាបលើចលនារបស់សហជីព។ ក្រុមហ៊ុនទេសចរណ៍កាពីតូលបានរំលោភយ៉ាងបំពានទៅលើសិទ្ធិការងារ និងសេរីភាពមូលដ្ឋានរបស់និយោជិតខ្លួន ហើយយើងសូមថ្កោលទោសចំពោះទង្វើរបស់ក្រុមហ៊ុននេះ។

ម្យ៉ាងទៀត យើងសូមរំលឹកសារជាថ្មីនូវការថ្កោលទោស[1] ចំពោះហិង្សាដ៏ឃោរឃៅកើតឡើងកាលពីថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលបង្កដោយសមាជិករបស់សមាគមរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជា (“ស.រ.អ.ក”) ដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុនទេសចរណ៍កាពីតូល ព្រមទាំងភាពអសកម្មរបស់នគរបាលដែលមិនបានរារាំងបញ្ឈប់អំពើហិង្សា។ យើងសូមទទូចឲ្យសាលាដំបូងរាជធានីភ្នំពេញ មេត្តាចាត់វិធានការដើម្បីធានាឱ្យអ្នកទាំងនោះទទួលខុសត្រូវចំពោះអំពើហិង្សានេះ ដោយអនុលោមតាមច្បាប់ និងធានាថារាល់ការចោទប្រកាន់ទៅលើជនរងគ្រោះដែលគ្មានកំហុស អ្នកដែលឈរមើលព្រឹត្តិការណ៍ និងមេដឹកនាំសហជីពឯករាជ្យទាំងអស់ត្រូវបានទំលាក់ចោល។

ក្រុមហ៊ុនទេសចរណ៍កាពីតូលបានបដិសេធដាច់ខាតក្នុងការអនុញ្ញាតឱ្យនិយោជិតរបស់ខ្លួនបង្កើតសហជីព បើទោះជាពួកគេមានសិទ្ធិស្របច្បាប់ក្នុងការបង្កើតសហជីពក៏ដោយ។ មកដល់ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០១៥ ក្រុមហ៊ុនទេសចរណ៍កាពីតូលបានបណ្ដេញអ្នកបើកបរចំនួន ៤៥ នាក់ បន្ទាប់ពីអ្នកទាំងនោះបានគាំទ្រ និងព្យាយាមបង្កើតសហជីពដើម្បីទាមទារលក្ខខណ្ឌការងារល្អប្រសើរ។ បើទោះបីជាក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញ សេចក្ដីបញ្ជាកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ឲ្យក្រុមហ៊ុនអនុញ្ញាតឲ្យកម្មករចូលធ្វើការវិញ និងដីកាសម្រេចក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញចុះថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០១៥ ឲ្យកម្មករចូលធ្វើការវិញក្នុងរយៈពេល៤៨ម៉ោងក៏ដោយ ក៏ភាគីក្រុមហ៊ុនមិនអនុវត្តតាមនីតិវិធីច្បាប់ ហើយបានបន្តយាយីដល់អតីតអ្នកបើកបរទាំងនោះដែលព្យាយាមអនុវត្តសិទ្ធិការងារ និងសេរីភាពមូលដ្ឋានរបស់ខ្លួន។ ការបណ្ដេញ

---

[1] នេះជាការយោងទៅលើសេចក្ដីថ្លែងការណ៍រួមចេញដោយអង្គការសង្គមស៊ីវិលកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៦

អតីតអ្នកបើកបររថយន្តទាំងនេះ និងការបង្ក្រាបទៅលើសកម្មជនផ្សេងទៀតបាននាំឱ្យមានការតវ៉ាជាបន្តបន្ទាប់នឹងក្រុមហ៊ុនទេសចរណ៍កាពីតូល។

ព្រឹត្តិការណ៍ហិង្សានាពេលថ្មីៗបានកើតឡើងនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ នៅខាងក្រៅទីស្នាក់ការក្រុមហ៊ុនទេសចរណ៍កាពីតូលក្នុងខណ្ឌ៧មករា រាជធានីភ្នំពេញ ក្នុងអំឡុងពេលការតវ៉ាដោយសន្តិវិធីរបស់អតីតក្រុមអ្នកបើកបររថយន្តប្រមាណចំនួន ៥០ នាក់និងអ្នកគាំទ្រពួកគេ។ អ្នកបើកបរម៉ឺកទេសចរណ៍មួយក្រុមមានគ្នាប្រហែលចំនួន៥០ នាក់បានវាយនឹងដំបង របាដែក និងញញួរ និងស្នាប់ដៃយ៉ាងដំណំទៅលើអ្នកតវ៉ាដែលបានធ្វើឱ្យមនុស្សចំនួន ១៤ នាក់រងរបួស។ ព្រឹត្តិការណ៍ទាំងមូលត្រូវបានអ្នកឃ្លាំមើលសិទ្ធិមនុស្សថតបានជាវីដេអូឃ្លីប ។[2] បើទោះជាមានអំពើហិង្សាឃោរឃៅនេះក្តី នគរបាលមិនបានអន្តរាគមន៍ និងមានការលើកឡើងថាមាននគរបាលមួយចំនួនបានចូលរួមក្នុងអំពើហិង្សានោះទៀតផង។[3] អ្នកបង្កអំពើហិង្សាទាំងនោះមិនត្រូវបានចាប់ខ្លួនឡើយ ចំណែកឯជនរងគ្រោះចំនួនពីរនាក់ត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលតវ៉ានោះ ហើយត្រូវបានចោទប្រកាន់នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ពីបទរារាំងអជ្ញាធរសាធារណៈនិងរាំងចរាចរណ៍។[4] នៅថ្ងៃដដែល មេដឹកនាំសហជីពលេចធ្លោចំនួនបួននាក់ រួមមាន លោក អាត់ ធន់ ប្រធានសហភាពការងារកម្ពុជា លោកគង់ អាទិត្យ អគ្គលេខាធិការសហភាពការងារកម្ពុជាលោក សុខ ឈុនអឿង ប្រធានសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា និងលោក អៀន គឹមហ៊ុន លេខាធិការនៃសហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា ក៏ត្រូវបានចោទប្រកាន់ពីបទល្មើសចំនួនបីដូចគ្នាផងដែរ បើទោះបីជាពួកគាត់មិនមានវត្តមាននៅក្នុងព្រឹត្តិការណ៍កាលពីថ្ងៃទី០៦ កុម្ភៈ ឆ្នាំ២០១៦ នោះក៏ដោយ ។[5]

អំពើហិង្សានេះបានប្រព្រឹត្តដោយផ្ទាល់ពីសំណាក់ក្រុមអ្នកបើកបរម៉ឺកទេសចរណ៍ដែលមានទំនាក់ទំនងជាមួយស.រ.អ.ក ដែលមានប្រវត្តិតវ៉ាប្រឆាំងនឹងក្រុមអង្គការសង្គមស៊ីវិលឯករាជ្យ។ ស.រ.អ.ក មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងរដ្ឋាភិបាល និងសាលារាជធានីភ្នំពេញ ដែលបានជួយឱ្យក្រុមនេះចុះកិច្ចសន្យាជាមួយក្រុមហ៊ុនជាច្រើនក្នុងនោះរួមមានក្រុមហ៊ុនទេសចរណ៍កាពីតូល និងផ្សារទំនើបអ៊ីអនផងដែរ។ នាពេលកន្លងមក ស.រ.អ.ក បានធ្វើបាតុកម្មនៅខាងមុខការិយាល័យសង្គមស៊ីវិលមួយចំនួនជាការឆ្លើយតបទៅនឹងការគាំទ្ររបស់គេដល់សកម្មជនដីធ្លីនៅសហគមន៍បឹងកក់ ដែលបានជាប់ពន្ធនាគារ គឺលោកស្រី យ៉ោម បុប្ផា។[6] យើងជឿជាក់ថា សកម្មភាពដែលធ្វើឡើងដោយ សមាជិក ស.រ.អ.ក កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ មិន

---

[2] លីកាដូ អ្នកបើកបររថយន្តកាពីតូលត្រូវបានមនុស្សស្លៀកពាក់ស៊ីវិលវាយដំ វាយដំ យូធូប (ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦) សូមចូលទៅកាន់តំណះ http://bit.ly/1Q2mv2j ដើម្បីទស្សនាវីដេអូឃ្លីប។

[3] លីកាដូ "សង្គមស៊ីវិលថ្កោលទោសយ៉ាងធ្ងន់ធ្ងរចំពោះអំពើហិង្សាទៅលើអតីតអ្នកបើកបររថយន្តកាពីតូល" (ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦) http://bit.ly/1LukE0P

[4] នឹម ឆេង " អតីតអ្នកបើកបររថយន្តក្រុងកាពីតូលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើវាយតប់គ្នា" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦)។

[5] សេក ឧត្តម "ប្រធានសហជីពរិះគន់ការចោទប្រកាន់ជុំវិញការតវ៉ាប្រឆាំងនឹងក្រុមហ៊ុនទេចរណ៍កាពីតូល" សារព័ត៌មាន*ខេមបូឌា ដេលី* (ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២) http://bit.ly/1KXtoS1

[6] ផាក ស៊ាងលី "អ្នករត់ម៉ូតូឌុបធ្វើការតវ៉ានៅមុខអង្គការលីកាដូ" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២*
http://goo.gl/vPvDEX

បង្ហាញអំពីធន្ទះភាគច្រើនរបស់សមាជិក ស.រ.អ.ក នោះទេ ដូច្នេះយើងអំពាវនាវឲ្យសមាជិក ស.រ.អ.ក ថ្កោល ទោសអំពើហិង្សានេះ និងអោយថ្នាក់ដឹកនាំរបស់ ស.រ.អ.ក ទទួលខុសត្រូវទៅលើការវាយប្រហារនេះ។

ហេតុការណ៍នាពេលថ្មីៗនេះបង្ហាញពីការវិវត្តគួរឱ្យព្រួយបារម្ភមួយចំនួនដូចជា ការបញ្ឈប់បុគ្គលិក ដែលមានបំណងអនុវត្តសិទ្ធិស្របច្បាប់របស់ខ្លួនក្នុងការបង្កើតសហជីព ការប្រើក្រុមមនុស្សដើម្បីប្រព្រឹត្តអំពើហិង្សាដ៏ឃោរឃៅជួសមុខឱ្យក្រុមហ៊ុន ការបណ្តែតបណ្តោយរបស់អាជ្ញាធរចំពោះអំពើហិង្សាដោយបរាជ័យក្នុងការធ្វើអន្តរាគមន៍ និងការមិនគោរពតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ការឃាយឹតាមប្រព័ន្ធតុលាការមកលើថ្នាក់ដឹកនាំសហជីពទាំង៤ នាក់គឺបង្ហាញពីការបង្ក្រាបជាប្រព័ន្ធរបស់រដ្ឋាភិបាលទៅលើចលនាសហជីពទាំងមូលផងដែរ។ ប្រការនេះកំពុងតែធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង ជាពិសេសទាក់ទងនឹងមាត្រា ២៩ នៃសេចក្តីស្នើច្បាប់ស្តីពីសហជីពដែលផ្តល់សិទ្ធិឱ្យធ្វើការរំលាយសហជីពមួយបានចំពោះ "ការប្រព្រឹត្តមិនត្រឹមត្រូវ" របស់ថ្នាក់ដឹកនាំណាម្នាក់។

យើងសូមទាមទារឱ្យក្រុមហ៊ុនទេសចរណ៍កាពីតូលទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះការរំលោភបំពានសិទ្ធិការងារ និងសេរីភាពមូលដ្ឋានរបស់និយោជិតខ្លួន។ យើងក៏សូមស្នើឱ្យសាលាដំបូងរាជធានីភ្នំពេញចាត់វិធានការដើម្បីធានាថា ក្រុមហ៊ុនទេសចរណ៍កាពីតូលមិនទទួលនិទណ្ឌភាពចំពោះទង្វើរបស់ខ្លួន និងធានាថាសិទ្ធិរបស់ជនរងគ្រោះត្រូវបានគោរពត្រឹមត្រូវស្របតាមវិធាននីតិរដ្ឋ។ ប្រសិនបើមិនទទួលបានតាមលក្ខខណ្ឌទាមទារខាងក្រោមនេះទេ យើងនៅតែអំពាវនាវឱ្យសាធារណជនចូលរួមធ្វើពហិការប្រើប្រាស់សេវាក្រុមហ៊ុនទេសចរណ៍កាពីតូល ៖

១. ទម្លាក់ចោលបទចោទប្រឆាំងនឹងអ្នកតវ៉ា និងថ្នាក់ដឹកនាំសហជីពទាំងប្រាំមួយនាក់ជាបន្ទាន់

២. ចោទប្រកាន់ដល់ជនដែលប្រព្រឹត្តអំពើហិង្សាមកលើអ្នកតវ៉ា

៣. ទទួលយកអតីតអ្នកបើកបរទាំង ៤៥ នាក់ដែលត្រូវបានបញ្ឈប់ឱ្យចូលបម្រើការងារនៅក្រុមហ៊ុនកាពីតូលវិញ និងគិតប្រាក់រំលឹកគិតចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ។

ជាងនេះទៅទៀត យើងសូមអំពាវនាវដល់សាធារណជនចូលរួមពហិការដើម្បីគាំទ្របុគ្គលិកទាំង ៤៥ ដែលត្រូវបានបណ្តេញចេញពីក្រុមហ៊ុនកាពីតូល ដែលជាជនរងគ្រោះនៃអំពើឃោរឃៅកាលពីថ្ងៃទី០៦ ខែកុម្ភៈ និងចលនាសហជីពទាំងមូល។

**ក្រុមសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ រួមមាន ៖**

| ល.រ | នាមអង្គការសង្គមស៊ីវិល | នាមអ្នកចូលរួម | លេខទំនាក់ទំនង |
|---|---|---|---|
| ១ | *សម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ANSA Cambodia)* | *លោក សន ជ័យ* | 012 445 642 |
| ២ | *ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)* | *កញ្ញា ស្រី សុជាវី* | 017 990 371 |

| | | | |
|---|---|---|---|
| ៣ | មជ្ឈមណ្ឌលអាមេរិចកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (មជ្ឈមណ្ឌលសាមគ្គីភាព) | វីលៀម ខនខ្លីន | 077 222 020 |
| ៤ | សហគមន៍បូឌីញ | អ្នកស្រី ឌី សុផាន់ណាម៉ារ៉ានី | 012 216 805 |
| ៥ | សហគមន៍ដីធ្លីបឹងកក់(ភ្នំពេញ) | អ្នកស្រី ទេព វន្នី | 012 604 648 |
| ៦ | សហគមន៍បឹងត្របែក | លោក យុត ប៊ុនថាន | 012 214 237 |
| ៧ | សហគមន៍បុរីកីឡា | អ្នកស្រី ឆាយ គឹមហ៊ន | 017 522 303 |
| ៨ | អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV) | លោកស្រី ព្រំ ផល្លីក្លូង | 012 307 027 |
| ៩ | សមាគមអភិវឌ្ឍន៍ជីវភាពពលរដ្ឋកម្ពុជា | អ្នកស្រី កេន ឆេងឡាង | 012 366 859 |
| ១០ | សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា (CTWF) | លោក អៀន គឹមហ៊ុន | 010 379 253 |
| ១១ | សម្ព័ន្ធសហជីពកម្ពុជា (CATU) | លោកស្រី យ៉ាង សោភណ្ឌ | 089 336 601<br>016 930 706 |
| ១២ | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) | អ្នកស្រី ឆាយ ឈុនលី | ០១៧ ៥២៨ ០២១ |
| ១៣ | មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) | លោក ប៉ា ងួនទៀង | 012 598 066 |
| ១៤ | បណ្តាញកម្មករធ្វើការងារតាមផ្ទះកម្ពុជា | អ្នកស្រី យឹម សុធី | 078 711 494 |
| ១៥ | សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្ម កម្ពុជា | លោក កង វីណា | 272 247 012 |
| ១៦ | គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ~សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) | លោក សួន ប៊ុនស័ក្តិ | 092 344 357 |
| ១៧ | សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) | លោក ធន់ សារ៉ាយ | 016 440 044 |
| ១៨ | សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA) | លោក ឃុន រ៉ាន់ | 016 909 384 |
| ១៩ | សមាគមកម្មករសេដ្ឋកិច្ចក្រៅប្រពន្ធ័កម្ពុជា (CIWA) | លោក សុខ ឈុនអឿង | 093 716 653<br>012 716 653 |

| | | | |
|---|---|---|---|
| ២០ | សហភាពការងារកម្ពុជា (CLC) | លោក អាត់ ធន់ | 012 998 906 |
| ២១ | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) | អ្នកនាង ណាលី ពីឡូក | 012 803 650 |
| ២២ | បណ្ដាញយុវជនកម្ពុជា (CYN) | លោក ទឹម ម៉ាឡៃ | 017 990 689 |
| ២៣ | សង់ត្រាល់ (CENTRAL) | លោក មឿន តុលា | 093 556 643 |
| ២៤ | សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម (CISA) | លោក ហ៊ឹម យន់ | 012 947 022 |
| ២៥ | សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) | លោក ថេង សាវឿន | 015 225 088 |
| ២៦ | គណៈកម្មាធិការ ដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) | លោក គល់ បញ្ញា | 012 942 017 |
| ២៧ | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) | លោក ញឹក សារិន | 012 800 561 |
| ២៨ | DAN Church Aid (DCA) | | |
| ២៩ | Diakonia | អ្នកស្រី ណេវ៉ា ធួន | 012 465 117 |
| ៣០ | សហគមន៍បណ្ដាញអតីតស្ត្រីបឹងកក់ | អ្នកស្រី អ៊ឹម ស្រីទូច | 070 306 607 |
| ៣១ | អង្គការយេនឌ័រ និងអភិវឌ្ឍន៍នៅកម្ពុជា (GADC) | លោកស្រី រស់ សុភាព | 012 627 857 |
| ៣២ | ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) | លោក សៀ ភារម្យ | 012 852 325 |
| ៣៣ | សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) | លោក វន់ ពៅ | 012 534 796 |
| ៣៤ | យុវជនជនជាតិដើមភាគតិច ឃុំប្រមេ ស្រុកត្បែងមានជ័យខេត្តព្រះវិហារ | លោក លូត សាង | 097 456 6466 |
| ៣៥ | សមាគម ឥន្ទ្រទេវី (IDA) | លោកស្រី ឌី វដ្ឋា | 012 897 161 |
| ៣៦ | សមាគមយុវជនខ្មែរ (KYA) | លោកស្រី សិទ្ធ ហុងអៀង | 017 788 955 |
| ៣៧ | សហគមន៍ដីធ្លីភូមិ ១ ក្រុងព្រះសីហនុ | អ្នកស្រី ហង្ស ចិន្តា | 012 680 435 |

| | | | |
|---|---|---|---|
| ៣៨ | សហគមន៍ដីធ្លី ភូមិព្រែកជីក ឃុំជី២ក្រោម ខេត្ត កោះកុង | អ្នកស្រី ផាវ ញ៉ឹង | 093 456 704 |
| ៣៩ | សហគមន៍ដីធ្លីឡពាង ខេត្តកំពង់ឆ្នាំង | អ្នកស្រី អ៊ំ សុភី | 078 705 936 |
| ៤០ | អង្គការមាតាធម្មជាតិ (MN) | លោក អាឡិចហ្សង់ឌ្រូ ហ្គុន ហ្សាឡេហ្ស ដាវីដសុន | |
| ៤១ | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និង សន្តិភាព (PDP-Center) | លោក យ៉ង់ គឹមអេង | 016 828 211 |
| ៤២ | អង្គការពន្លកខ្មែរ (Ponlok Khmer) | លោក អាង ជាតិឡោម | 012 517943 |
| ៤៣ | សហគមន៍ផ្លូវរថភ្លើងទួលសង្កែ A | លោក ស៊ីម វីរៈ | 069 907 983 |
| ៤៤ | សមាគមជាងត្នោត (STT) | លោក អ៊ី សារុំ | 012 836 533 |
| ៤៥ | សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិ ភ្នំពេញ | អ្នកស្រី ប្រាយ នីម | 016 536 900 |
| ៤៦ | ស្តារកម្ពុជា (SK) | អ្នកស្រី ជេត ចរិយា | 012 802 460 |
| ៤៧ | អង្គការស្ត្រីខ្មែរ (SKO) | លោកស្រី អរុណា រស្មី | 012 236 653 |
| ៤៨ | សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើ កម្ពុជា (BWTUC) | លោក សុខ គីន | 012 736 270 |
| ៤៩ | សហព័ន្ធបុគ្គលិកទេសចរកម្ពុជា (CTSWF) | លោក ម៉ម រិទ្ធី | 012 411 755 |
| ៥០ | អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) | លោក ជាង សុខា | 011 928 418 |